ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ :...២៦/១៨...ប.ស.ស

ថ្ងៃច័ន្ទ ១រោច ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តនូវបទបញ្ញត្តិជាធរមានចំពោះសហគ្រាស គ្រឹះស្ថាន ដែលយឺតយូរក្នុងការបង់ភាគទាន និងការផ្តល់របាយការណ៍ចំនួនកម្មករ និយោជិត (ទម្រង់ ២.០១)មកបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)

អនុលោមតាមប្រកាសលេខ ៤៤៨ កប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម និងប្រកាសលេខ ៤៤៩ កប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកំណត់អត្រាភាគទាន បែបបទ និងនីតិវិធីនៃការបង់ភាគទាន សម្រាប់ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព ប.ស.ស សូមជូនដំណឹងដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលបានចុះបញ្ជីសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុង ប.ស.ស រួចហើយ ឲ្យបានជ្រាបថា៖ ដើម្បីធានាបាននូវសិទ្ធិ និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៨ តទៅ ប.ស.ស នឹងអនុវត្តយ៉ាងតឹងរឹងតាមបទបញ្ញត្តិជាធរមាន ចំពោះសហគ្រាស គ្រឹះស្ថានទាំងឡាយណា ដែលយឺតយូរក្នុងការបង់ភាគទាន និងការផ្តល់របាយការណ៍កម្មករនិយោជិតប្រចាំខែ ។

**សេចក្តីបញ្ជាក់** :
- ការបង់ភាគទានសម្រាប់ខែនីមួយៗ ត្រូវធ្វើឡើងយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់
- ការផ្តល់របាយការណ៍ចំនួនកម្មករ និយោជិត (ទម្រង់ ២.០១) និងឯកសារចាំបាច់ផ្សេងៗមកបេឡាជាតិរបបសន្តិសុខសង្គម ត្រូវធ្វើឡើងយ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
នាយកបេឡាជាតិរបបសន្តិសុខសង្គម

អ៊ិត សមហ៊ៀង

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ . ០២៣ ៨៨ ១០ ១៥
០២៣-៨៨ ១០ ១៦ . ០២៣ ៨៨ ០៤ ១៧
ទូរសារ : ០២៣ ៨៨ ២៦ ២៣. ប្រអប់សំបុត្រ P.O.Box 70
Website : www.nssf.gov.kh